01008801

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 08 / 2014
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [signature]

E307/3/2/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

សាធារណៈ / Public

ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៤

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលា ដំបូង**

**កម្មវត្ថុ:** **សេចក្តីសម្រេចទៅលើសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន សុំពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅលើសារណារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង**

១. នៅក្នុងសវនាការបឋមបន្ថែម ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានស្នើដោយផ្ទាល់មាត់ សុំពេលវេលាបន្ថែមដើម្បីអាចឆ្លើយតបទៅនឹងសារណារបស់សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលដាក់ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E307/3/2 និងE307/6)។ បន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្កើនចំនួនទំព័រលើសចំនួនកំណត់សម្រាប់ការដាក់សារណារបស់ពួកគេ (ឯកសារ E307/3/11) នោះ ចំនួនទំព័រនៃសារណារបស់សហព្រះរាជអាជ្ញាគឺមានចំនួន ៤២ ទំព័រ (ជាភាសា អង់គ្លេស) និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានចំនួន៣០ទំព័រ(ជាភាសាអង់គ្លេស)។ ក្រុមមេធាវី

ការពារក្តី ខៀវ សំផន បានលើកឡើងថា ដោយសារតែមានការបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាទាំងនេះ នោះ ក្រុមមេធាវីការពារក្តី ខៀវ សំផន ត្រូវការពេលវេលាលើសពីការកំណត់រយៈពេល ១០ ថ្ងៃ (ដែលអនុញ្ញាតដោយមាត្រា ៨.៣ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក) ដើម្បីឆ្លើយតបទៅនឹងសារណាខាងលើ។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីបានស្នើសុំពេលវេលាបន្ថែមចំនួន ១០ ថ្ងៃ បន្ថែមទៀត (ប្រតិចារឹកសវនាការ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៧៦-៧៧)។

២. នៅថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងទៅភាគីពាក់ព័ន្ធតាមរយៈអ៊ីម៉ែលថា អង្គជំនុំជម្រះបានឯកភាពតាមសំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ។ នាពេលនេះ អង្គជំនុំជម្រះសូមបញ្ជាក់ជាផ្លូវការថា ក្រុមមេធាវីការពារក្តី ខៀវ សំផន មានពេលវេលាបន្ថែមចំនួន ១០ ថ្ងៃ ដើម្បីឆ្លើយតបទៅនឹងឯកសារ E307/3/2 និង E307/6។